# សេដាក ផ្តល់បច្ចេកទេសដល់កសិករអោយចេះបន្សុទ្ធពូជស្រូវ

កសិករនៅក្នុងសហគមន៍អង្គការ សេដាក ដែលជាអ្នកពូកែខាងផលិតស្រូវសរីរាង្គតាមគោលការណ៍ធម្មជាតិ បានជួបជុំគ្នាពីពេលថ្មីៗនេះពិនិត្យមើលការធ្វើស្រូវបែបនេះវិញ ដើម្បីធ្វើអោយប្រសើរថែមទៀត ទៅលើគុណភាពស្រូវបែបនេះជាថ្មីឡើងវិញ ដើម្បីធ្វើអោយប្រសើរថែមទៀតទៅលើគុណភាពស្រូវ-អង្ករ សំរាប់លក់នាំចេញ ។

តាមរបាយការណ៍របស់លោកនង សំអាត អ្នកសំរបសំរួលសហព័ន្ធស្រូវសរីរាង្គបានលើកឡើងក្នុងអង្គប្រជុំ ដែលប្រព្រឹត្តិទៅនៅឃុំទ្រពាំងធំខាងត្បូងស្រុកត្រាំកក់ បានអោយដឹងថា សេដាក បានប្រមូលទិញស្រូវសរីរាង្គពីបណ្តាញសហគមន៍ទូទាំងប្រទេសពេលប្រមូលផលនៅចុងឆ្នាំ ២០០៨ ដើមឆ្នាំ ២០០៩ បានចំនួន ១.៣៨ តោនលើគំរោង ៤.000 តោន។ ការទិញនេះមានកាយឺតយ៉ាវ និងទិញមិនអស់ស្រូវពីសហគមន៍ ដោយសារការរអាក់រអួលបញ្ហាលុយយឺត។ ស្រូវសរីរាង្គនេះអង្គកា សេដាក គ្រោងផលិតជាអង្ករ នឹងត្រៀមនាំទៅសហរដ្ឋអាមេរិក នឹងប្រទេសអាល្លឺម៉ង់ ប្រមាណ ៤00 តោនអង្ករហើយក៏មានធ្វើចរាចរលក់ក្នុងប្រទេសរាល់ថ្ងៃផងដែរ។ តាមរយៈសាច់អង្ករ ដែលឃើញ និងពិនិត្យជាមួយដៃគូនាំចេញ បានបង្ហាញថា កសិករនៅក្នុងសហគមន៍នៅមិនទាន់សិរិតសំរាំងពូជស្រូវសំរាប់ផលិតឱ្យមានគុណភាពខ្ពស់នៅឡើយទេ។ លោកបណ្ឌិតយ៉ង សាំងកុមារ ប្រធានអង្គការ សេដាក បានរំលឹកកសិករទាំងអស់អោយចេះរើសយកពូជស្រូវ ដែលល្អគឺនៅពាក់កណ្តាល នៃគួរស្រូវនីមួយៗ។ ហើយយកទៅសាបដាំ និងអនុវត្តស្របតាមវិធីសាស្ត្រ ១២ ចំនុចរបស់ប.វ.ស។ ពេលច្រូតកាត់ ស្រូវដែលច្រូតកាត់បានល្អ ហើយអង្ករមិនបាក់ច្រើន គឺត្រូវច្រូតនៅពេលស្រូវទុំរវាង ៨0 ទៅ ៨៥ ភាគរយ។ លោកប្រធានអង្គការ បានបញ្ជាក់ទៀតថា ចំពោះកាបោកបែន ចំនុចដែលល្អគឺគេត្រូវបោកដោយដៃ ។ ការបញ្ជាន់ស្រូវដោយគោក្របីធ្វើអោយគ្រាប់ស្រូវខូចគុណភាពឬបាក់គ្រាប់អង្ករ។ ការបោកដោយម៉ាស៊ីន បើស្រូវសើមអាចបាក់ពី ២0 ទៅ ២៥ ភាគរយ។ កាហាលស្រូវដោយកន្ទេល ល្អជាងស្រូវហាលដោយកំរាលឥដ្ឋ។ ដូច្នះកសិករយើងត្រូវធ្វើយ៉ាងណាព្យាយាមបន្សុទ្ធពូជអោយបានល្អ។ ការទុកដាក់ពូជត្រូវមានខ្យល់ចូលដល់គ្រាប់ពូជ។ កត្តានេះធ្វើឱ្យអង្ករមានគុណភាព ធ្វើឱ្យការនាំចេញមានភាពងាយស្រួល និងមានតំលៃខ្ពស់។ ឥឡូវនេះក្រុមសហគមន៍កសិករផលិតស្រូវសរីរាង្គ បានអនុវត្តនៅក្នុង ៣.៣៧៥ ភូមិក្នុងខេត្តទាំង ២0 ទូទាំងប្រទេស ។ ក្នុងនោះកសិករប្រមាណ ១00.000 គ្រួសារ បានទទួលប្រយោជន៍ ពីការធ្វើស្រែសរីរាង្គតាមគោលការណ៍ធម្មជាតិនេះ។

